**នៅចំពោះអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ:**

សំណុំរឿងលេខ: ០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៤៧)

ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: ភាសាអង់គ្លេស

កាលបរិច្ឆេទដាក់ឯកសារ: ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០

**ចំណាត់ថ្នាក់ឯកសារ:**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ អបជ សម្ងាត់/Confidential/Confidentiel សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន: 21/07/2011

ឈ្មោះមន្ត្រីកត់ត្រា: Peang Tola

ហត្ថលេខា:

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Dec-2010, 08:52
CMS/CFO: Ly Bunloung

---

**ការឆ្លើយតបទៅនឹងចម្លើយតបរបស់ការិយាល័យរដ្ឋបាល**

---

**ដាក់ដោយ:**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោកស្រី Silke STUDZINSKY

**ដាក់ជូនទៅ:**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន ប្រធាន

ចៅក្រម Rowan DOWNING

ចៅក្រម ន៉ីយ ថុល

ចៅក្រម Catherine MARCHI-UHEL

ចៅក្រម ហួត វុទ្ធី

**ចម្លងជូន**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew T. CAYLEY

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

លោក គង់ ពិសី

លោក យុង ផានិត

លោក គឹម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ជេត វណ្ណលី

លោក ពេជ អង្គ

លោក ហ៊ីន ពៅ

លោក ឡោ ជុនធី

លោកស្រី ស៊ិន សុវ៉ន

លោក ហុង គឹមសួន

លោកស្រី Martine JACQUIN

លោក Philippe CANONNE

លោកស្រី Elizabeth RABESANDRATANA

លោកស្រី Annie DELAHAIE

លោក Olivier BAHOUGNE

លោកស្រី Lyma NGUYEN

លោក Mahdev MOHAN

លោកស្រី Marie GUIRAUD

លោក Patrick BAUDOIN

លោកស្រី Fabienne TRUSSES-NAPROUS

**មេធាវីការពារក្ដី អៀង សារី**

លោក អាង ឧត្ដម

លោក Michael G. KANAVAS

**មេធាវីការពារក្ដី អៀង ធីរិទ្ធ**

លោក ផាត់ ពៅសៀង

លោកស្រី Diana ELLIS

**មេធាវីការពារក្ដី នួន ជា**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Vector COPPE

**មេធាវីការពារក្ដី ខៀវ សំផន**

លោក ស ស្វាន

លោក Jacques VERGES

លោក Philippe GRECIANO

---

លោក Ferdinand DJAMMEN-NZEPA

លោកស្រី Christine MARTINEAU

លោកស្រី Laure DESFORGES

លោកស្រី Isabelle DURAND

លោក Emmanuel ALTIT

លោក Emmanuel JACOMY

លោក Daniel LOSQ

លោក Julien RIVET

លោក Pascal AUBOIN

លោកស្រី Françoise GAUTRY

លោក Barnabe NEKUIE

## I. ប្រវត្តិ

១. កាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះ (“អបជ”) បានសម្រេចទៅលើបណ្តឹងឧទ្ធរណ៍[១] របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។ អបជ បានអញ្ជើញសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីដទៃទៀតដែលបានរៀបរាប់ឈ្មោះនៅក្នុងកថាខណ្ឌ៩ កថាខណ្ឌ១៤ កថាខណ្ឌ១៥ និងកថាខណ្ឌ ២៦ នៃចម្លើយតបរបស់ការិយាល័យរដ្ឋបាល (“ចម្លើយតប”)[២] ទៅតាមលទ្ធភាពរបស់ពួកគេ ដើម្បីធ្វើការឆ្លើយតប[៣]។

២. ចម្លើយតបនេះលើកឡើងយ៉ាងច្បាស់នូវឈ្មោះរបស់លោកស្រី Lyma NGUYEN និងម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងចំណោមមេធាវីចំនួនប្រាំមួយរូប មកពីក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីរក្រុមផ្សេងគ្នា។ តាមរយៈនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍សូមធ្វើការឆ្លើយតបទៅតាមលទ្ធភាពរបស់ខ្លួន។

៣. ការអញ្ជើញឱ្យធ្វើការឆ្លើយតប ត្រូវបានជូនដំណឹងដល់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០។ យោងតាមមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ សំណើឆ្លើយតបចំពោះសារណាតប ត្រូវដាក់ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃនៃប្រតិទិន។ ដោយសារថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១០ គឺជាថ្ងៃអាទិត្យ នោះកាលបរិច្ឆេទដាក់ការឆ្លើយតបគឺត្រូវដាក់នៅថ្ងៃធ្វើការបន្ទាប់ មានន័យថា ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០។

ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថា កាលបរិច្ឆេទចំនួនបីថ្ងៃ ក្នុងចំណោមប្រាំថ្ងៃ គឺស្ថិតចំថ្ងៃឈប់សម្រាក និង/ឬស្ថិតចំចុងសប្តាហ៍។ ដោយសារតែ អង្គភាពបកប្រែភាសា (“ITU”) មិនធ្វើការ

---

[១] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើស្តីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០, ឯកសារលេខ D410/2/1។

[២] ចម្លើយតប ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០, ឯកសារលេខ D410/2/2។

[៣] សេចក្តីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើសេចក្តីសន្និដ្ឋានលាយលក្ខណ៍អក្សរ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០, ឯកសារលេខ D410/2/3, ទំព័រ៣។

00631077



នៅថ្ងៃឈប់សម្រាក និងនៅចុងសប្តាហ៍ នោះមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនអាចដាក់ការឆ្លើយតប នៅក្នុងអំឡុងកាលបរិច្ឆេទកំណត់ជាពីរភាសាបានទេ។ អាស្រ័យហេតុនេះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើ អបជ ដោយក្តីគោរពមេត្តាអនុញ្ញាតឲ្យដាក់ជូនការឆ្លើយតបជាភាសាអង់គ្លេសជាមុនសិន ចំណែកការឆ្លើយតបជាភាសាខ្មែរវិញ នឹងត្រូវដាក់ជូននៅពេលបកប្រែរួចរាល់។

## II. សេចក្តីសង្ខេបបឋម

៤. ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថា ការអញ្ជើញរបស់ អបជ ឲ្យធ្វើការឆ្លើយតបគឺស្របទៅនឹងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ និងត្រូវបានអនុញ្ញាត តែនៅក្នុងករណីមិនមានការកំណត់កាលបរិច្ឆេទបើកសវនាការសួរដេញដោលផ្ទាល់មាត់។ មាត្រា ៨.៤ សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ផ្ទុះបញ្ចាំងពីគោលការណ៍ទូទៅ និងជាសារវ័ន្ត នៃសិទ្ធិទទួលបានការកាត់សេចក្តីតាមផ្លូវច្បាប់។ វាជាការចាំបាច់ណាស់ដែលត្រូវលើកឡើងពីចំណុចនេះ ដោយសារថា ការអញ្ជើញរបស់ អបជ ឲ្យធ្វើការឆ្លើយតបនេះ បានបណ្តាលឲ្យមានការមិនសប្បាយចិត្ត និងការភ្ញាក់ផ្អើលនៅក្នុងចំណោមអង្គភាពមួយចំនួននៃសាលាក្តីនេះ។

៥. គួរកត់សម្គាល់ចាប់តាំងដើមដំបូងមកថា ក្នុងចំណោម "មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងដប់ពីរក្រុម"[៤] ភាគច្រើនគឺជាមេធាវីអន្តរជាតិ ដែលធ្វើការរួមគ្នាជាមួយមេធាវីជាតិតែមួយ ហើយពួកគេមិនបំពេញការងារជាអចិន្ត្រៃយ៍នៅក្នុងប្រទេសកម្ពុជានោះទេ ហើយការមិនបំពេញការងារជាប្រចាំនេះគឺដោយសារមិនមានថវិកាគ្រប់គ្រាន់ ដើម្បីបង្កលក្ខណៈឲ្យពួកគេធ្វើដំណើរមកកាន់ប្រទេសកម្ពុជាជាអចិន្ត្រៃយ៍ និងបំពេញការងារជាមេធាវីការពារជនក្រីក្រ ដោយមិនយកកម្រៃ ឬយ៉ាងច្រើនបំផុតទទួលបានប្រាក់ឧបត្ថម្ភបន្តិចបន្តួច តាមរយៈអង្គការស្ម័គ្រចិត្តមួយចំនួន។ មានមេធាវីជាតិ និងអន្តរជាតិ ព្រមទាំងជំនួយការ ប្រហែលជាមិនលើសពី ១៦ (ដប់ប្រាំមួយ) នាក់ទេដែលកំពុងបំពេញការងារជាអចិន្ត្រៃយ៍នៅក្នុងប្រទេសកម្ពុជា។

[៤] សូមមើល កថាខណ្ឌ ១០ នៃចម្លើយតប។

៦. ការិយាល័យរដ្ឋបាលបានចោទប្រកាន់ ម្ចាស់បណ្តឹងឧទ្ធរណ៍ថា បានស្វែងរក "វិធានការតាមផ្លូវតុលាការ"[៥]។ ការស្វែងរកដំណោះស្រាយតាមផ្លូវតុលាការនេះ គឺជាសិទ្ធិរបស់ភាគីទាំងឡាយដែលចូលរួមក្នុងដំណើរការនីតិវិធី ហើយវាមិនមែនជាការរំលោភលើកាតព្វកិច្ចវិជ្ជាជីវៈ ដូចបានលើកឡើងនៅក្នុងចម្លើយតបនោះទេ។ លើសពីនេះទៅទៀត ការស្នើសុំឱ្យការិយាល័យរដ្ឋបាលផ្តល់ការគាំទ្រផ្នែករដ្ឋបាលដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺជាសិទ្ធិមួយដែលបានទទួលស្គាល់ដោយវិធានផ្ទៃក្នុង និងមិនអាចយកមកអះអាងថាជា "ការរំខាន"[៦] បានឡើយ។

៧. វាជាការគួរឱ្យបារម្ភយ៉ាងខ្លាំង ដែលការិយាល័យរដ្ឋបាលធ្វើការចោទប្រកាន់ធ្ងន់ៗមកលើ "មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុម" ដោយគ្មានមូលហេតុ គ្មានមូលដ្ឋានត្រឹមត្រូវ និងហាក់ដូចជាមានអារម្មណ៍ខឹងសម្បារ ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈភាសាអុជអាល ដែលបានយកមកប្រើប្រាស់ជាការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ដែលមានមូលដ្ឋានអង្គហេតុ និងប្រកបដោយហេតុផល ជាជាងការលើកឡើងនូវការពិតឱ្យបានត្រឹមត្រូវទៅវិញ។ ការចោទប្រកាន់ដោយមិនមានមូលហេតុ និងមិនមានមូលដ្ឋានគាំទ្រ ថាបានរំលោភទៅលើក្រមសីលធម៌មេធាវី បង្កើតបានជាការបង្ខូចកេរ្តិ៍ឈ្មោះ និងធ្វើឱ្យការបំពេញកិច្ចការដ៏ត្រឹមត្រូវ និងកិត្តិយសរបស់មេធាវីទាំងឡាយដែលបានរៀបរាប់ឈ្មោះ ប្រឈមមុខទៅនឹងហានិភ័យ។ សរុបមក ម្ចាស់បណ្តឹងឧទ្ធរណ៍សូមច្រានចោលនូវការចោទប្រកាន់ទាំងអស់ ដែលបានលើកឡើងដោយមិនត្រឹត្រូវ និងមិនដែលពិតទាល់តែសោះនោះ។

៨. ម្ចាស់បណ្តឹងឧទ្ធរណ៍កត់សម្គាល់បន្ថែមទៀតថា មានតែកថាខណ្ឌ១ និងកថាខណ្ឌ១៧ នៃចម្លើយតបតែប៉ុណ្ណោះដែលមានមូលដ្ឋានត្រឹមត្រូវពេញលេញ។

## III. **ការចោទប្រកាន់ថាបានរំលោភទៅលើបទប្បញ្ញត្តិស្តីពីការកំណត់ទីលំនៅវិជ្ជាជីវៈ**

៩. នៅក្នុងចម្លើយតបរបស់ខ្លួន ការិយាល័យរដ្ឋបាលបានចោទប្រកាន់ថា "ជាពិសេស លោកស្រី Lyma NGUYEN និងម្ចាស់បណ្តឹងឧទ្ធរណ៍ មិនបានអនុវត្តតាម [មាត្រា១ នៃក្រមសីលធម៌

---

[៥] សូមមើល កថាខណ្ឌ ៩ នៃចម្លើយតប។ សូមមើល កថាខណ្ឌ ២៥ ដល់ ២៦ នៃចម្លើយតបផងដែរ។

[៦] សូមមើល កថាខណ្ឌ ២៥ ដល់ ២៦ នៃចម្លើយតប។ សូមមើល វិធាន ១២ នៃវិធានផ្ទៃក្នុង ផងដែរ។

មេធាវី]"[៧] ដែលចែងថា មេធាវីទាំងឡាយនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ទីលំនៅវិជ្ជាជីវៈដើមរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។

១០. ម្ចាស់បណ្តឹងឧទ្ធរណ៍កត់សម្គាល់ឃើញថា រយៈកាលកន្លងមក នៅក្នុងបរិបទនៃ អវតក លក្ខខណ្ឌនៃការទទួលចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់មេធាវីអន្តរជាតិ គឺខុសគ្នាពីលក្ខខណ្ឌទាំងឡាយសម្រាប់មេធាវីជាតិ ដោយសារ (i) មេធាវីអន្តរជាតិត្រូវបានកម្រិតឱ្យអនុវត្តតែនៅក្នុងយុត្តាធិការរបស់ អវតក តែប៉ុណ្ណោះ និង (ii) មេធាវីអន្តរជាតិមានកាតព្វកិច្ចបំពេញកិច្ចការជាមួយមេធាវីជាតិ ចំណែកឯមេធាវីជាតិត្រូវបានអនុញ្ញាតឱ្យអនុវត្តយុត្តាធិការនេះតែឯងបាន។

១១. លើសពីនេះទៅទៀត ខុសពីតុលាការជាតិ អវតក គឺជាតុលាការដែលប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកដែលអាចទទួលព័ត៌មានបានពេញលេញពីកុំព្យូទ័រ នៅក្នុងរង្វង់បណ្តាញការងាររបស់តុលាការនេះតែប៉ុណ្ណោះ។ ចំណែកឯការទទួលបានឯកសារតាមប្រព័ន្ធ Zylab ពីចម្ងាយអាចត្រូវបានអនុញ្ញាតការបំពេញការងារពីក្រៅប្រទេសត្រូវមានកម្រិត ឬមិនអាចបើកមើលតាមប្រព័ន្ធអេឡិចត្រូនិករបស់ អវតក បានទេ រួមទាំងកម្មវិធីចាំបាច់មួយចំនួនដើម្បីបំពេញការងារឱ្យបានពេញលេញ និងត្រឹមត្រូវ ដូចជា (Case Map, Text Map, Shared Network G និង S drives ជាដើម)។ ដើម្បីឱ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីធ្វើជាតំណាងកូនក្តីរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ នោះការទទួលបានឯកសារដោយរលូន និងឆាប់រហ័ស តាមរយៈប្រព័ន្ធ និងកម្មវិធីទាំងនេះ គឺជាការចាំបាច់ និងខានមិនបាន។

១២. ដោយសារតែឧបសគ្គខាងផ្នែកបច្ចេកទេសទាំងនេះ និងការចែករំលែកការិយាល័យរួមគ្នានៅក្នុងតុលាការនេះ នោះម្ចាស់បណ្តឹងឧទ្ធរណ៍បានកំណត់យកទីលំនៅវិជ្ជាជីវៈរបស់ខ្លួននៅក្នុងបរិវេណ អវតក (គឺនៅក្នុងប្រទេសកម្ពុជា) ចាប់តាំងពីពេលដែលខ្លួនបានចុះបញ្ជីជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នៅខែមីនា ឆ្នាំ២០០៨ មកម្ល៉េះ។ អាស្រ័យហេតុនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានរំលោភក្រមសីលធម៌មេធាវីនោះទេ។

---

[៧] សូមមើល កថាខណ្ឌ ១៤ នៃចម្លើយតប។

១៣. ការិយាល័យដំបូងរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ គឺនៅបន្ទប់លេខ ៤២៩ ក្នុងអាគារធំរបស់តុលាការនេះ។ ការិយាល័យទីពីរ គឺនៅជាន់ផែល ហើយការិយាល័យទីបី គឺនៅបន្ទប់លេខ C១៣១ ចំណែកឯ ការិយាល័យទីបួន គឺនៅបន្ទប់លេខ ១០០ នៃមជ្ឈមណ្ឌលព័ត៌មានរបស់តុលាការនេះ។ ការិយាល័យនៅខាងក្រោយអាហារដ្ឋាន ទើបតែកសាងថ្មីសម្រាប់អង្គភាពជនរងគ្រោះ (សព្វថ្ងៃដូចឈ្មោះមកជាអង្គភាពគាំពារជនរងគ្រោះ) ហើយបន្ទប់ភាគច្រើនកសាងឡើងសម្រាប់តែមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។ ចាប់តាំងពីពេលបង្កើតតុលាការនេះមក ម្ចាស់បណ្ដឹងឧទ្ធរណ៍ គឺជាមេធាវីអន្តរជាតិតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីតែម្នាក់គត់ ដែលបានបំពេញការងារជាអចិន្ត្រៃយ៍នៅក្នុងប្រទេសកម្ពុជា[៨]។ គួរកត់សម្គាល់ផងដែរថា ការិយាល័យរដ្ឋបាលបានប្រគល់កូនសោរមកឲ្យម្ចាស់បណ្ដឹងឧទ្ធរណ៍ និងជំនួយការរបស់គាត់ សម្រាប់បន្ទប់នីមួយៗ (លើកលែងតែបន្ទប់លេខ ១០០ ដែលជាបន្ទប់មួយបើកចំហ) ហើយតាមរយៈជំនួយការនៃបុគ្គលិករបស់ អវតក បានរៀបចំការផ្ទេរឯកសារ សម្ភារៈទាំងអស់ រួមទាំង កុំព្យូទ័រ ដែលបានចុះជាបញ្ជីពីការិយាល័យមួយទៅការិយាល័យមួយទៀត។ ក្នុងរយៈពេលជិតបីឆ្នាំកន្លងមកនេះ និងឆ្លងកាត់ការផ្លាស់ប្ដូរការិយាល័យទាំងបួនលើក សំណុំឯកសារ និងធនធានដទៃទៀត គឺស្ថិតនៅក្នុងអាគារតុលាការនេះគ្រប់ពេលវេលា។

១៤. ការប្ដូរទីតាំងចុងក្រោយទៅកាន់ការិយាល័យតុលាការក្នុងទីក្រុង នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១០ គឺធ្វើឡើងតាមការណែនាំរបស់ការិយាល័យរដ្ឋបាល ដែលបានចាត់ចែងឡើងជាក់លាក់ទៅតាមជាន់របស់ការិយាល័យនេះ នូវទីតាំងដែលត្រូវដាក់តុ កុំព្យូទ័រ ធ្នើរដាក់ឯកសារ និងទូរដាក់ឯកសាររបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍នៅក្នុងបន្ទប់លេខ ១០០។ ក្រោយមក នៅពេលដែលមេធាវីទទួលការឧបត្ថម្ភថវិកាពីតុលាការ ចាកចេញពីបន្ទប់លេខ ១០៣ នៃការិយាល័យប្រចាំក្នុងក្រុង មកកាន់បន្ទប់ជាប់គ្នា សហមេធាវីនាំមុខជាតិបច្ចុប្បន្ន ដែលបានទទួលសេចក្ដីណែនាំពីប្រធានអង្គភាពគាំពារជនរងគ្រោះ បានអញ្ជើញម្ចាស់បណ្ដឹងឧទ្ធរណ៍ដោយផ្ទាល់មាត់ និងយ៉ាងច្បាស់ឲ្យយកឯកសារទាំងអស់ចេញពីបន្ទប់លេខ ១០៣។ សំណើឲ្យរើចេញពីបន្ទប់នេះបានធ្វើឡើងក្នុងដំណាក់កាលដ៏មមាញឹក និងតឹងតែង នៅពេលដែលមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីកំពុងតែជាប់រវល់ជាមួយនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្ដីពីការទទួល

[៨] លោកស្រី Lyma NGUYEN បានចាប់ផ្ដើមធ្វើការពេញម៉ោងនៅក្នុងប្រទេសកម្ពុជា នៅខែកក្កដា ឆ្នាំ២០១០ ។

យកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ ការរុះរើមកកាន់បន្ទប់លេខ ១០៣ មិនត្រូវបានធ្វើឡើងឡើយ។ បន្ថែមលើនេះទៅទៀត ម្ចាស់បណ្តឹងឧទ្ធរណ៍មិនមានបំណងចង់បានឯកសិទ្ធិបន្ថែមទៀតក្នុងឋានៈជាមេធាវីអន្តរជាតិ ដូចជា ការមានបន្ទប់ផ្ទាល់ខ្លួនដែលអាចចាក់សោរបិទ-បើកបាន (បន្ទប់លេខ១០៣) នោះទេ ក្នុងពេលដែលសហភាគីជាតិមិនបានទទួលលក្ខខណ្ឌការងារប្រហាក់ប្រហែលគ្នានោះ។

១៥. ក្នុងអំឡុងពេលជិតបីឆ្នាំ ដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានបំពេញការងារជាអចិន្ត្រៃយ៍នៅក្នុងការិយាល័យមួយក្នុងបរិវេណរបស់តុលាការនេះ ការិយាល័យរដ្ឋបាល/អង្គភាពគាំពារជនរងគ្រោះមិនបានជំទាស់ម្តងណាឡើយ។ ការមិនមានការជំទាស់នេះ គឺជាការបញ្ជាក់ឲ្យឃើញថា ការិយាល័យរដ្ឋបាល/អង្គភាពគាំពារជនរងគ្រោះ បានយល់ព្រមទៅនឹងការរៀបចំកន្លែងធ្វើការនេះ។ ការិយាល័យរដ្ឋបាលថែមទាំងបានជួយដល់ការរុះរើការិយាល័យមួយលើកៗ ដោយជួយចង្អុលបង្ហាញទីកន្លែងដែលត្រូវដាក់តុ-ទូ ឲ្យបានត្រឹមត្រូវថែមទៀតផង។

១៦. ម្ចាស់បណ្តឹងឧទ្ធរណ៍កត់សម្គាល់ឃើញថា ការិយាល័យរដ្ឋបាល/អង្គភាពគាំពារជនរងគ្រោះ បានផ្លាស់ប្តូរមនោសញ្ចេតនា និងគោលនយោបាយរបស់ខ្លួនអំពីការប្រព្រឹត្តមកលើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទើបតែពេលថ្មីៗនេះទេ គឺនៅពេលដែលមានការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេត។ បណ្តឹងឧទ្ធរណ៍នេះត្រូវបានចាត់ថ្នាក់ថាជាការសម្ងាត់ ប៉ុន្តែ ត្រូវបានអញ្ញត្រជនប្រាប់ទៅប្រធានអង្គភាពគាំពារជនរងគ្រោះ មុននឹង អបជ ធ្វើការអញ្ជើញការិយាល័យរដ្ឋបាលឲ្យឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍នេះ។

១៧. លើសពីនេះទៅទៀត ម្ចាស់បណ្តឹងឧទ្ធរណ៍សូមលើកឡើងជាថ្មីម្តងទៀតថា ភាគច្រើននៃមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីដែលទទួលប្រាក់ឧបត្ថម្ភពីតុលាការ រួមទាំងមេធាវីជាតិ និងអន្តជាតិដទៃទៀត មិនដែលបានបង្កើតការិយាល័យនៅខាងក្រៅតុលាការទេ ដោយសារតែចំនុចជាក់លាក់មួយចំនួនរបស់តុលាការនេះ ដូចដែលបានលើកឡើងខាងលើ។

១៨. សរុបសេចក្តីមក ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានរំលោភលើក្រមសីលធម៌មេធាវីនោះទេ។ ដូចមេធាវីដទៃទៀតដែរ ម្ចាស់បណ្តឹងឧទ្ធរណ៍បានកំណត់ទីលំនៅវិជ្ជាជីវៈរបស់ខ្លួននៅក្នុងប្រទេសកម្ពុជានៅក្នុងបរិវេណតុលាការនេះ។ ការកំណត់បែបនេះត្រូវបានទទួលស្គាល់ដោយការិយាល័យរដ្ឋបាល

កាលពីពេលកន្លងមក និងតាមពិតទៅ ត្រូវបានការិយាល័យរដ្ឋបាលជួយសម្របសម្រួលថែមទៀតផង។

១៩. យោងតាមមូលហេតុដែលបានលើកឡើងខាងលើ បញ្ហាភាពសម្ងាត់ដែលទាក់ទងទៅនឹងលក្ខខណ្ឌការងារនៅឯមជ្ឈមណ្ឌលព័ត៌មានសាធារណៈរបស់ អវតក គឺជាបញ្ហាដែលត្រូវដោះស្រាយដោយការិយាល័យរដ្ឋបាល មិនមែនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកដោះស្រាយ ដូចដែលបានលើកឡើងទាំងមិនត្រឹមត្រូវក្នុងកថាខណ្ឌ ១៦ ដល់ ១៩ នៃចម្លើយតបនោះទេ។

## IV. ការចោទប្រកាន់ចំពោះការរំលោភមាត្រា ២៥ នៃក្រមសីលធម៌មេធាវី

២០. ចម្លើយតបរបស់ការិយាល័យរដ្ឋបាលបានចោទប្រកាន់ថា មានការរំលោភលើមាត្រា ២៥ នៃក្រមសីលធម៌មេធាវី និងមានការប្រព្រឹត្តមិនត្រឹមត្រូវ មិនសមរម្យ ដោយមាក់ងាយ និងរើសអើងចំពោះសហភាតាដែលបានទទួលប្រាក់ឧបត្ថម្ភពីតុលាការ[៩]។ ចម្លើយតបនេះអះអាងបន្ថែមទៀតថា មេធាវីដែលបានដាក់បណ្តឹងឧទ្ធរណ៍ បានសាកសួរកូនក្តីរបស់ក្រុមមេធាវីដែលបានទទួលប្រាក់ឧបត្ថម្ភពីតុលាការ ដោយពុំមានការអនុញ្ញាតពីក្រុមមេធាវីនេះឡើយ[១០]។

២១. ម្ចាស់បណ្តឹងឧទ្ធរណ៍សូមបដិសេធយ៉ាងដាច់អហង្ការចំពោះការចោទប្រកាន់ទាំងនេះ។

២២. ម្ចាស់បណ្តឹងឧទ្ធរណ៍មិនដែលមានការទាក់ទងដោយមិនត្រឹមត្រូវជាមួយកូនក្តីរបស់មេធាវី ដែលទទួលប្រាក់ឧបត្ថម្ភពីតុលាការទេ និងមិនដែលបាន "សាកសួរ" កូនក្តីទាំងនោះឡើយ[១១]។ លើសពីនេះទៅទៀត ចាប់តាំងពីពេលចាប់ផ្តើមបំពេញការងាររបស់ខ្លួននៅ អវតក ម្ចាស់បណ្តឹងឧទ្ធរណ៍បានរក្សាទំនាក់ទំនងជាមួយសហភាតាទាំងអស់ដោយក្តីគោរពយ៉ាងជ្រាលជ្រៅបំផុត រួមទាំងសហភាតាជាតិផង ទោះជាសហភាតាទាំងនោះបានទទួលការឧបត្ថម្ភថវិកាពីតុលាការក្តី ឬមិនបានទទួលប្រាក់ឧបត្ថម្ភពីតុលាការក្តី។ ចំនុចនេះត្រូវបានស្តែងឡើងតាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់

[៩] សូមមើល កថាខណ្ឌ ២២ ដល់ ២៤ នៃចម្លើយតប។

[១០] សូមមើល កថាខណ្ឌ ២២ នៃចម្លើយតប។

[១១] សូមមើល កថាខណ្ឌ ២២ នៃចម្លើយតប។

ខ្លួន បន្ថែមលើការងារផ្នែកច្បាប់ប្រចាំថ្ងៃ ព្រមទាំងតាមរយៈសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពដើម្បីបង្កើនវិជ្ជាជីវៈ និងជំនាញរបស់មេធាវីជាតិឲ្យកាន់តែប្រសើរឡើង និងការបណ្តុះបណ្តាលតាមរយៈការងារជាក់ស្តែងអំពីបញ្ហាច្បាប់ និងនីតិវិធី នៅទូទាំងដំណើរការនីតិវិធីក្នុងសំណុំរឿង ០០១ និង ០០២។ ភាតរភាពនេះត្រូវបានបង្កើតឡើងក្នុងស្មារតីសាមគ្គីភាព និងក្នុងឆន្ទៈគោរពគ្នាទៅវិញទៅមក ដើម្បីរៀនសូត្រពីគ្នាទៅវិញទៅមក ស្របតាមកាតព្វកិច្ច និងក្រមសីលធម៌វិជ្ជាជីវៈ។

២៣. ការដែលដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនពេញចិត្ត និងរីករាយឲ្យមានមេធាវីជាតិ និងមេធាវីអន្តរជាតិតំណាងនៅក្នុងតុលាការកូនកាត់មួយនេះ និងឲ្យមានតំណាងការពារផ្លូវច្បាប់ដូចគ្នាទៅនឹងមេធាវីការពារក្តី (ក៏ដូចជាផ្នែកផ្សេងទៀតនៅក្នុងតុលាការនេះ) គឺកើតចេញពីសេចក្តីថ្លែងរបស់កូនក្តីជាច្រើនរបស់ម្ចាស់បណ្តឹងឧទ្ទរណ៍។ លើសពីនេះទៅទៀត កូនក្តីជាច្រើនរបស់ម្ចាស់បណ្តឹងឧទ្ទរណ៍បានបញ្ជាក់ថា វត្តមានរបស់មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងបុគ្គលិកអន្តរជាតិ គឺបានផ្តល់នូវជំនឿទុកចិត្តដល់ពួកគាត់ថា ដំណើរការនីតិវិធីនឹងត្រូវបានប្រព្រឹត្តទៅស្របតាមបទដ្ឋានអន្តរជាតិ។

## V. គោលបំណងនៃការផ្លាស់ប្តូរការិយាល័យសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពីតុលាការទៅកាន់មជ្ឈមណ្ឌលព័ត៌មាន និងការយកបុគ្គលិករបស់អង្គភាពគាំពារជនរងគ្រោះពីការិយាល័យក្នុងទីក្រុងមកកាន់តុលាការ

២៤. មូលហេតុដែលបានលើកឡើងក្នុងចម្លើយតបរបស់ការិយាល័យរដ្ឋបាល សម្រាប់ការផ្លាស់ប្តូរការិយាល័យរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចេញពីបរិវេណតុលាការ ទៅកាន់មជ្ឈមណ្ឌលព័ត៌មានសាធារណៈរបស់ អវតក និងការយកបុគ្គលិករបស់អង្គភាពគាំពារជនរងគ្រោះមកកាន់បរិវេណតុលាការ គឺជាការមិនត្រឹមត្រូវដោយផ្នែកខ្លះ។ ចម្លើយតបបញ្ជាក់ថា ការផ្លាស់ប្តូរទីកន្លែងនេះគឺដើម្បី (i) សម្របសម្រួលដល់កិច្ចការរបស់អង្គភាពគាំពារជនរងគ្រោះ (ii) សម្របសម្រួលដល់ការជួបប្រជុំក្នុងចំណោមក្រុមអ្នកច្បាប់ និង (iii) សម្របសម្រួលដល់ការប្រាស្រ័យទាក់ទងគ្នារវាងមេធាវី និងកូនក្តី។

២៥. ទាក់ទងទៅនឹងអត្ថប្រយោជន៍របស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដូចបានលើកឡើងថា ការផ្លាស់ប្ដូរទីកន្លែងទៅកាន់មជ្ឈមណ្ឌលព័ត៌មាន គឺដើម្បីសម្របសម្រួលការជួបជាមួយកូនក្ដី គឺមិនមែនជាការត្រឹមត្រូវនោះទេ។ ដើមបណ្ដឹងរដ្ឋប្បវេណីភាគច្រើនបំផុត គឺមកពីតំបន់ជនបទដាច់ស្រយាល តាមបណ្ដាខេត្តនានានៃប្រទេសកម្ពុជា។ ពួកគាត់មិនមានលទ្ធភាពធ្វើដំណើរមកកាន់តុលាការ ឬមជ្ឈមណ្ឌលព័ត៌មានដោយមិនមានធនធានបានទេ។ មុននឹងមានការផ្លាស់ប្ដូរការិយាល័យទាំងនេះ ការជួបប្រជុំជាមួយកូនក្ដីមួយចំនួនតូចមកពីរាជធានីភ្នំពេញត្រូវបានធ្វើឡើងនៅក្នុងបន្ទប់ប្រជុំនៃមជ្ឈមណ្ឌលព័ត៌មានសាធារណៈ។ ការិយាល័យរដ្ឋបាលមិនដែលមានការពិគ្រោះយោបល់ម្ដងណា ថាតើការផ្លាស់ប្ដូរកន្លែងធ្វើការទៅកាន់ការិយាល័យនៅក្នុងទីក្រុងពិតជាសម្រួលដល់ការជួបជាមួយកូនក្ដីឬអត់នោះទេ ហើយការិយាល័យរដ្ឋបាលក៏មិនបានពន្យល់ថាតើការផ្លាស់ប្ដូរការិយាល័យអាចសម្រួលឲ្យមេធាវីជួបជាមួយកូនក្ដីទាំងឡាយដែលកាលពីមុនមិនមានមធ្យោបាយធ្វើដំណើរមកកាន់ទាំងបរិវេណតុលាការ ទាំងបន្ទប់ប្រជុំនៃមជ្ឈមណ្ឌលព័ត៌មាននៅក្នុងក្រុង។

២៦. សរុបមក មិនមានហេតុផលណាមួយដែលបានលើកឡើងសម្រាប់ការផ្លាស់ប្ដូរទីកន្លែងធ្វើការ គឺធ្វើឡើងដើម្បីជាអត្ថប្រយោជន៍មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។

## VI. សេចក្ដីសន្និដ្ឋាន

២៧. យោងតាមហេតុផលដែលបានលើកឡើងខាងលើ គេអាចសន្និដ្ឋានបានថា ការផ្លាស់ប្ដូរការិយាល័យគឺសំអាងទៅលើហេតុផលផ្សេង ជាជាងការសម្របសម្រួល និងគាំទ្រដល់កិច្ចការរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទៅវិញទេ។ ការផ្លាស់ប្ដូរនេះមានផលប៉ះពាល់ដល់ការងាររបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយការផ្លាស់ប្ដូរការិយាល័យជាចុងក្រោយទៅកាន់ការិយាល័យនៅខាងក្រៅបណ្ដាញប្រព័ន្ធអេឡិចត្រូនិករបស់ អវតក នាពេលនេះ គឺកាន់តែធ្វើឲ្យខូចប្រយោជន៍ដល់ការបំពេញការងារឲ្យបានត្រឹមត្រូវ របស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីថែមទៀត។ ការចោទប្រកាន់ខ្លាំងៗ និងធ្ងន់ៗចំពោះការរំលោភក្រមសីលធម៌មេធាវី និងកាតព្វកិច្ចវិជ្ជាជីវៈ គឺមិនមានមូលដ្ឋានអ្វីជាសំអាងនោះទេ និងហេតុដូច្នេះ ត្រូវចាត់ទុកជាមោឃៈ។

២៨. អាស្រ័យហេតុនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍សំណូមពរដោយក្តីគោរពឲ្យ អបជ៖

(i) ទទួលយកការឆ្លើយតបនេះក្នុងរង្វង់កាលបរិច្ឆេទកំណត់ តែភាសាអង់គ្លេសជាមុនសិន។

(ii) បដិសេធការចោទប្រកាន់ដែលមាននៅក្នុងចម្លើយតបរបស់ការិយាល័យរដ្ឋបាល។

(iii) ច្រានចោលសំណើសុំរបស់ការិយាល័យរដ្ឋបាល ដែលស្នើសុំឲ្យមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅ "បំពេញការងារនៅទីលំនៅវិជ្ជាជីវៈរបស់ពួកគេ ឬនៅតាមបណ្តាអង្គការដែលបានឧបត្ថម្ភដល់ពួកគេ"។

(iv) បដិសេធរាល់សំណើដទៃទៀតរបស់ការិយាល័យរដ្ឋបាល និង

(v) សម្រេចទៅលើបណ្តឹងឧទ្ធរណ៍នេះ ដោយធ្វើឲ្យលក្ខខណ្ឌការងាររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានស្តង់ដារការងារប្រហាក់ប្រហែលគ្នាទៅនឹងភាគីដទៃទៀតនៅក្នុងដំណើរការនីតិវិធី។

សូមលោកចៅក្រមមេត្តាទទួលយកបណ្តឹងឧទ្ធរណ៍នេះដោយអនុគ្រោះ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០

លោកស្រី Silke STUDZINSKY
សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី